# អនុសញ្ញាស្តីពីសិទ្ធិជនពិការ

## ជាអត្ថបទសម្រាយក្រៅផ្លូវការ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ

*កម្ពុជា*

ខែធ្នូ ឆ្នាំ២០១១

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា

ក្របរូបភាពដោយការិយាល័យ OHCHR នៅកម្ពុជា

នេះគឺជាការបោះពុម្ពផ្សាយដោយ
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។
អត្ថបទសម្រាយក្រៅផ្លូវការនេះ
គ្រាន់តែជាឯកសារធ្វើឲ្យងាយស្រួលយល់តែប៉ុណ្ណោះ
មិនមែនជាឯកសារដែលមានតំលៃស្មើនឹងអត្ថបទផ្លូវការឡើយ។
ក្នុងករណីមានមន្ទិល សូមយោងទៅរកឯកសារផ្លូវការជាភាសាអង់គ្លេស។

# មាតិកា

សេចក្តីផ្តើម.......................................................................................................១
បុព្វកថា..............................................................................................................៦
១- អនុសញ្ញានេះ..................................................................................................១៣
២- ពាក្យសំខាន់ៗក្នុងអនុសញ្ញានេះ.........................................................................១៣
៣- គំនិតជាមូលដ្ឋាន.............................................................................................១៤
៤- ប្រទេសជាសមាជិក...........................................................................................១៥
៥- ត្រូវស្មើភាពគ្នា..................................................................................................១៧
៦- ស្ត្រីពិការ..........................................................................................................១៧
៧- កុមារពិការ.......................................................................................................១៨
៨- ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីពិការភាព.........................................................១៨
៩- ការបង្កលក្ខណៈងាយស្រួល..............................................................................១៩
១០- សិទ្ធិរស់រានមានជីវិត......................................................................................២០
១១- គ្រាមានអាសន្ន...............................................................................................២១
១២- ត្រូវបានប្រព្រឹត្តលើដោយស្មើភាពគ្នានៅចំពោះមុខច្បាប់......................................២១
១៣- ការទទួលបានសេវាកម្មយុត្តិធម៌.........................................................................២២
១៤- មានសេរីភាព និងសុវត្ថិភាព..............................................................................២៣
១៥- មិនត្រូវទទួលរងទារុណកម្ម..............................................................................២៤
១៦- មិនត្រូវបានគេបំពាន ឬប្រើប្រាស់.......................................................................២៥
១៧- ការប្រព្រឹត្តមកលើជនពិការជាដំបូង ថាជាមនុស្ស..............................................២៦
១៨- ការផ្លាស់ប្តូរពីកន្លែងមួយ ទៅកន្លែងមួយ..............................................................២៦

១៩- ការរស់នៅដោយឯករាជ្យ.....២៧
២០- ការចល័ត.....២៨
២១- និយាយពីអ្វីដែលចង់និយាយ និងការទទួលបានព័ត៌មាន.....២៨
២២- ភាពជាឯកជន.....២៩
២៣- ការគោរពលំនៅដ្ឋាន និងគ្រួសារ.....៣០
២៤- ការអប់រំ.....៣១
២៥- សុខភាព.....៣៣
២៦- សេវាកម្មនានា.....៣៤
២៧- ការងារ.....៣៥
២៨- កំរិតជីវភាពសមរម្យ.....៣៦
២៩- ចូលរួមក្នុងសកម្មភាពនយោបាយ.....៣៧
៣០- កីឡា និងការកំសាន្ត.....៣៨
៣១- ព័ត៌មាន.....៤០
៣២- ការរួមសហការគ្នា.....៤០
៣៣- ធ្វើឲ្យអនុសញ្ញានេះសំរេចបានជោគជ័យ.....៤១
៣៤- គណៈកម្មាធិការសិទ្ធិជនពិការ.....៤១
៣៥- របាយការណ៍.....៤២
៣៦- ការពិនិត្យរបាយការណ៍.....៤៣
៣៧- គណៈកម្មាធិការ និងប្រទេសសមាជិក.....៤៤
៣៨- ការងាររបស់គណៈកម្មាធិការសិទ្ធិជនពិការ.....៤៤
៣៩- របាយការណ៍របស់គណៈកម្មាធិការ.....៤៥
៤០- កិច្ចប្រជុំនៃប្រទេសសមាជិក.....៤៥

# អនុសញ្ញាស្តីពីសិទ្ធិជនពិការ

## សេចក្តីផ្តើម

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់ថា " មនុស្សទាំងអស់ កើតមកមានសេរីភាព និងសមភាព ក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ "។ ជនពិការក៏ដូចជាមនុស្សជាតិទាំងអស់ដែរ ត្រូវទទួលបានសិទ្ធិមនុស្សដូចគ្នា "ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ"។ គោលការណ៍សមភាព និងការមិនរើសអើង ត្រូវបានបញ្ជាក់ជាថ្មីនៅរាល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ ជាយថាហេតុ រាល់សន្ធិសញ្ញាសិទ្ធិមនុស្ស ការពារសិទ្ធិជនពិការ។ ជនពិការត្រូវទទួលបានយ៉ាងពេញលេញនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាថាជនពិការទាំងអស់ អាចទទួលបានសិទ្ធិរបស់ខ្លួនដោយមិនមានការរើសអើងនោះ មិនមែនជាការងាយស្រួលឡើយ ទោះជាមានការការពារដោយសន្ធិសញ្ញា ដែលមានជាធរមានក្តី ជនពិការ នៅតែប្រឈមមុខនឹងឧបសគ្គជាច្រើន ក្នុងការចូលរួមជាសមាជិកដោយស្មើភាពនៅក្នុងសង្គម និងទទួលរងការរំលោភបំពានលើសិទ្ធិមនុស្សរបស់ពួកគេនៅគ្រប់ទិសទីលើពិភពលោក។ ដោយហេតុនេះទើបនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសន្ធិសញ្ញាអន្តរជាតិថ្មីមួយ ដែលមានបំណងជាពិសេសលើកស្ទួយសិទ្ធិ ជនពិការ និងធានាថាជនពិការមានសិទ្ធិស្មើគ្នាជាមួយជនដទៃទៀត ដែលមានកាយសម្បទាគ្រប់គ្រាន់ពាក់ព័ន្ធនឹងការការពារសិទ្ធិពួកគេ។

មាត្រា៣នៃអនុសញ្ញានេះ បង្កើតសំណុំមួយនៃគោលការណ៍ទូទៅដូចជា ៖

ក- ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំង សេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល ។

ខ- ការមិនរើសអើង ។

គ- ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម ។

ឃ- ការគោរពជនពិការគ្រប់ប្រភេទ ហើយត្រូវទទួលស្គាល់ថា ជនពិការជាចំណែកនៃភាពចំរុះគ្នារបស់មនុស្ស និងមនុស្សជាតិ ។

ង- ឱកាសស្មើភាពគ្នា ។

ច- ការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ។

ឆ- សមភាពរវាងបុរស និងស្រ្តី ។

ជ- ការគោរពសមត្ថភាពរីកចំរើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ ។

គោលការណ៍ទូទៅទាំងនេះ បង្កើតជាមូលដ្ឋានដែលអនុសញ្ញានេះខិតខំដោះស្រាយពីសេចក្តីត្រូវការជាក់ស្តែងរបស់ជនពិការ ។

មាត្រា៥ ចែងអំពីសិទ្ធិគ្មានការរើសអើង និងភាពស្មើគ្នាដោយផ្តោតជាពិសេសលើជនពិការ និងអនុញ្ញាតជាពិសេសឱ្យមានវិធានការជាក់លាក់មួយចំនួន ប្រសិនជាចាំបាច់ ដើម្បីពន្លឿន ឬធ្វើអោយបានសំរេចនូវភាពស្មើគ្នាតាមព្រឹត្តន័យរបស់ជនពិការ ។

បន្ទាប់មក អនុសញ្ញានេះ ចែងពីគោលការណ៍ណែនាំទូទៅ ពីវិស័យដែលជាកង្វល់ជាក់ស្តែង ចំពោះការការពារសិទ្ធិមនុស្សរបស់ជនពិការ ។ មាត្រា៦ ចែងអំពីស្ថាន

ភាពស្ត្រីពិការ រួមទាំងបញ្ហានៃការរើសអើងជាច្រើននិងបន្ថែមការការពារដែលមាននៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ដូចគ្នានេះដែរ មាត្រា៧ ពង្រឹងកិច្ចការពារថែមទៀតចំពោះកុមារពិការដូចមានចែងក្នុងមាត្រា២៣នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ មាត្រា៨ លើកស្ទួយការយល់ដឹងដើម្បីប្រយុទ្ធប្រឆាំងនឹងការយល់ឃើញជាអវិជ្ជមាន និងការរើសអើង លើកស្ទួយការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ និងទទួលស្គាល់ការរួមវិភាគទានជាវិជ្ជមាន ដែលជនពិការ ធ្វើសំរាប់សង្គម។ មាត្រា៩ ធានាការពារជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ទទួលបាននូវបរិដ្ឋានជុំវិញខ្លួន ការដឹកជញ្ជូន ព័តិមាន និងទំនាក់ទំនង និងគ្រឿងផាសុបករណ៍ និងសេវាកម្មដទៃទៀត នៅកន្លែងដែលជនពិការ រស់នៅ ដូច្នេះហើយ ពួកគេអាចរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញ ក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅ។ មាត្រា១១ ចែងអំពីស្ថានការណ៍នៃគ្រោះថ្នាក់ ជាពិសេស ចំពោះជនពិការ រួមទាំងជំលោះប្រដាប់អាវុធ ជំនួយបន្ទាន់ខាងមនុស្សធម៌ និងគ្រោះធម្មជាតិ។

បន្ទាប់មក អនុសញ្ញានេះគូសបញ្ជាក់ពីសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គមកិច្ចយ៉ាងជាក់លាក់ ដែលបានទទួលស្គាល់ក្នុងសន្ធិសញ្ញាដទៃទៀតក្នុងទស្សនវិស័យខាងជនពិការ។ សិទ្ធិទាំងនេះ រួមមានសិទ្ធិរស់រានមានជីវិត ការទទួលស្គាល់ស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ សេរីភាព និងសន្តិសុខបុគ្គល សេរីភាពរួចផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេរីភាពរួចផុតពីការធ្វើអាជីវកម្ម អំពើហឹង្សានិងការរំលោភបំពាន ការការពារបូរណភាពរូបកាយ សេរីភាពក្នុងការដើរហើរ និងមានសញ្ជាតិ សិទ្ធិរស់នៅដោយឯករាជ្យ និងត្រូវបានដាក់បញ្ចូលទៅក្នុងសហគមន៍

ការចល័តជាបុគ្គល សេរីភាពក្នុងការសំដែងមតិនិងយោបល់ និងសិទ្ធិទទួលបានព័ត៌មាន ការគោរពសិទ្ធិឯកជន សិទ្ធិមានលំនៅដ្ឋាន និងសិទ្ធិមានគ្រួសារ សិទ្ធិទទួលបានការអប់រំ សុខភាព សិទ្ធិមានការរស់នៅស្របសមរម្យ និងការការពារផ្នែកសង្គមកិច្ច ការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម ការរកការងារធ្វើ និងការចូលរួមក្នុងជីវភាពសាធារណៈ និងនយោបាយ ជីវភាពវប្បធម៌ ការកំសាន្ត ការឈប់សំរាក និងកីឡា ។

អនុសញ្ញានេះ មានបទបញ្ញត្តិលំអិតអំពីការអនុវត្តន៍ និងការឃ្លាំមើលថ្នាក់ជាតិ រួមមានការប្រមូលស្ថិតិ និងទិន្នន័យដទៃទៀត និងមុខងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសំរេចតាមនិយាម ដែលជាបំណងប្រាថ្នារបស់អនុសញ្ញានេះសំរាប់ជាប្រយោជន៍ដល់ជនពិការ ។ ទន្ទឹមនឹងទិសដៅដែលបានកំណត់ក្នុងអនុសញ្ញានេះ មានតំលៃ និងចាំបាច់ ប្រទេសជាច្រើន នឹងត្រូវប្រឈមមុខពុះពារគ្រប់ឧបសគ្គដ៏ធំធេង ដើម្បីបំពេញនូវការបន្តប្តេជ្ញាចិត្តរបស់ខ្លួន ស្របតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ។ ដើម្បីជួយរដ្ឋនានាក្នុងការអនុវត្តន៍អនុសញ្ញានេះឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការដែលស្គាល់ថាជាគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ ត្រូវបានបង្កើតឡើង ។ រដ្ឋភាគីនីមួយៗត្រូវបានតម្រូវឱ្យដាក់ជូនរបាយការណ៍មួយតាមកាលកំណត់ ទៅគណៈកម្មាធិការនេះ ដោយកំណត់ពីវិធានការដែលត្រូវមាន ដើម្បីអនុវត្តអនុសញ្ញានេះ ។ បន្ទាប់មក គណៈកម្មាធិការ ត្រូវផ្តល់ការណែនាំ និងអនុសាសន៍ជំនាញ ចំពោះការចាត់វិធានការបន្តទៅទៀត ដើម្បីពង្រឹងការបន្តប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ចំពោះគោលដៅទាំងឡាយដែលបានកំណត់ដោយអនុសញ្ញានេះ ។

ជនពិការត្រូវបានប្រឈមមុខជាមួយឧបសគ្គជាច្រើន ក្នុងការទាមទារសិទ្ធិ

របស់ពួកគេ។ អាស្រ័យហេតុនេះ ទើបពិធីសារបន្ថែមលើអនុសញ្ញានេះបានផ្តល់សមត្ថកិច្ចបន្ថែមដល់គណៈកម្មាធិការនេះ ដើម្បីធ្វើការស៊ើបសួរនិងពិចារណាលើបណ្តឹងរបស់បុគ្គលពាក់ព័ន្ធនឹងការអនុវត្តន៍អនុសញ្ញានេះ ក្នុងប្រទេសទាំងឡាយ ដែលបានជ្រើសរើសទទួលយកនីតិវិធីនេះ។

អនុសញ្ញា និងពិធីសារបន្ថែមលើអនុសញ្ញានេះ បានចូលជាធរមានកាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨។។ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញានេះ និងពិធីសារបន្ថែម កាលពីថ្ងៃទី០១ តុលា ២០០៧ ហើយមានបំណងនឹងផ្តល់សច្ចាប័ន ក្នុងពេលដ៏ឆាប់តាមដែលអាចធ្វើទៅបាន។ នៅពេលដែលរដ្ឋាភិបាល ធ្វើដូច្នេះបាន សិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះ នឹងត្រូវបានធានាការពារដោយច្បាប់អន្តរជាតិ និងដោយរដ្ឋធម្មនុញ្ញកម្ពុជាតាមមាត្រា៣១។

ច្បាប់ស្តីពីកិច្ចការពារ និងលើកកំពស់សិទ្ធិជនពិការដែលរាជរដ្ឋាភិបាល បានរៀបចំធ្វើជាច្រើនឆ្នាំមកហើយនោះ ត្រូវបានសភាអនុម័ត ហើយព្រះមហាក្សត្របានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។ នៅមានលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានអនុម័តរួចហើយ និងកំពុងព្រាង ទាក់ទងនឹងវិស័យពិការភាព។ លិខិតបទដ្ឋានទាំងនេះ ត្រូវបានតាក់តែង តម្រូវតាមស្ថានការណ៍ជាក់ស្តែងក្នុងប្រទេសកម្ពុជា នឹងការពារបន្ថែមទៀតដល់ សិទ្ធិជនពិការនៅប្រទេសកម្ពុជា។

ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១

# អនុសញ្ញាស្តីពីសិទ្ធិជនពិការ
## បុព្វកថា

**រដ្ឋភាគីនៃអនុសញ្ញានេះ ៖**

ក- *ដោយរំលឹកឡើងវិញពី*គោលការណ៍ទាំងឡាយ ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងតម្លៃ ហើយនឹងសិទ្ធិស្មើគ្នា ដែលមិនអាចលក់ដូរបាន ដែលមានពីកំណើតនៃសមាជិកគ្រប់រូបក្នុងសង្គមមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក ។

ខ- *ដោយទទួលស្គាល់ថា* តាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបានប្រកាស និងបានយល់ព្រមថា មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាង ដូចដែលមានចែងក្នុងសេចក្តីប្រកាសជាសកល និងក្នុងកតិកាសញ្ញាអន្តរជាតិទាំងនេះ ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ។

គ- *ដោយគូសបញ្ជាក់ឡើងវិញថា* សកលភាព ភាពមិនអាចបំបែកបាន ភាពពំនាក់អាស្រ័យគ្នានិងភាពទាក់ទងគ្នានៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ព្រមទាំងសេចក្តីត្រូវការរបស់ជនពិការ ត្រូវបានធានាយ៉ាងពេញលេញដោយគ្មានការរើសអើង ។

ឃ-*ដោយរំលឹកឡើងវិញពី* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពល

រដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការប្រកាន់ពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តីពីកាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក អនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់កម្មករទេសន្តប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ។

ង- *ដោយទទួលស្គាល់ថា* ពិការភាព គឺជាទស្សនទានដែលមានការវិវត្ត ហើយពិការភាព កើតចេញពីអន្តរកម្មរវាងជនពិការ និងឧបសគ្គទាំងឡាយទាក់ទងទៅនឹងអាកប្បកិរិយា និងបរិយាកាសជុំវិញ ដែលរារាំងពួកគេមិនឱ្យចូលរួមក្នុងសង្គមបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

ច- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃគោលការណ៍ និងសេចក្តីណែនាំពីគោលនយោបាយ ដែលមាននៅក្នុងកម្មវិធីសកម្មភាពពិភពលោកទាក់ទងនឹងជនពិការ និងនៅក្នុងវិធានបមាណីនានាស្តី ពីការផ្តល់ឱកាសស្មើៗគ្នា ដល់ជនពិការ ដើម្បីបញ្ចូលជំរុញបង្កើត និងវាយតំលៃគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ ដើម្បីផ្តល់ឱកាសឱ្យបានស្មើៗគ្នាថែមទៀតដល់ជនពិការ។

ឆ- *ដោយគូសបញ្ជាក់បន្ថែមពី* សារៈសំខាន់នៃការបញ្ចូល

បញ្ហាពិការភាព ឲ្យទៅជាផ្នែកមួយពេញលេញ នៃយុទ្ធសាស្ត្រពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តភាព។

ជ- *ដោយទទួលស្គាល់ផងដែរថា* ការរើសអើងប្រឆាំងនឹងបុគ្គលណាម្នាក់ ដោយសារតែពិការភាព គឺជាការរំលោភលើសេចក្តីថ្លៃថ្នូរ និងតំលៃរបស់មនុស្សដែលមានពីកំណើត។

ឈ- *ដោយទទួលស្គាល់បន្ថែមទៀត* ពីពិការភាពផ្សេងគ្នារបស់ជនពិការ។

ញ- *ដោយទទួលស្គាល់ពីតម្រូវការលើកស្ទួយ* និងការពារសិទ្ធិមនុស្សរបស់ជនពិការគ្រប់រូប រួមទាំងអ្នកទាំងឡាយណាដែលត្រូវការគាំពារកម្រិតខ្ពស់។

ដ- *ដោយមានការបារម្ភថា* បើទោះជាមានឧបករណ៍ និងការធានារ៉ាប់រងផ្សេងៗយ៉ាងនេះក្តី ក៏ជនពិការនៅតែបន្តប្រឈមមុខនឹងឧបសគ្គក្នុងការចូលរួមរបស់គេដោយស្មើភាពគ្នា ជាមួយសមាជិកឯទៀតក្នុងសង្គម និងការរំលោភសិទ្ធិមនុស្សរបស់ពួកគេនៅទូទាំងពិភពលោក។

ឋ- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកម្ពស់ស្ថានភាពរស់នៅរបស់ជនពិការនៅគ្រប់ប្រទេស ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

ឌ- *ដោយទទួលស្គាល់ពី*វិភាគទានដ៏មានតំលៃ និងមានសក្តានុពលរបស់ជនពិការ ចំពោះសុខុមាលភាពទាំងស្រុងនិងភាពប្លែកៗគ្នានៃសហគមន៍របស់ខ្លួន និងការលើកស្ទួយជនពិការឱ្យទទួលបាន

ពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងការចូលរួម យ៉ាងពេញលេញរបស់ពួកគេក្នុងសង្គម សម្រេចបានជាលទ្ធផល គឺ ការលើកកម្ពស់សតិអារម្មណ៍របស់ជនពិការ ថា ខ្លួនជាផ្នែកមួយនៃ សង្គម និងភាពជឿនលឿនដ៏មានខ្លឹមសារក្នុងការអភិវឌ្ឍន៍មនុស្ស សង្គមកិច្ច និងសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រ។

ឍ- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃស្វ័យភាពជាឯកត្ត បុគ្គល និងឯករាជ្យភាពរបស់ជនពិការម្នាក់ៗ រួមទាំងសេរីភាពក្នុងការ មានជំរើសរបស់ខ្លួនផ្ទាល់។

ណ- *ដោយយល់ឃើញថា* ជនពិការគួរតែមានឱកាសចូលរួម យ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្ដីសម្រេចអំពីគោលនយោបាយនិង កម្មវិធីនានា រួមទាំងកិច្ចការដែលពាក់ព័ន្ធនឹងបញ្ហារបស់ពួកគេផ្ទាល់។

ត- *ដោយមានក្ដីកង្វល់អំពី* ស្ថានភាពលំបាកដែលជនពិការ បានជួបប្រទះ នូវការរើសអើងជាច្រើន ឬការរើសអើងដែលមានទម្រង់ ធ្ងន់ធ្ងរ ដែលឈរលើមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬទស្សនៈផ្សេងទៀត ជាតិ ជាតិពន្ធុ ប្រភពដើមជនជាតិ និងសង្គម ទ្រព្យសម្បត្តិ ដើមកំណើត អាយុ ឬឋានៈផ្សេងៗទៀត។

ថ- *ដោយទទួលស្គាល់ថា* ស្ត្រីនិងកុមារីពិការតែងតែជួបប្រទះ នូវភយន្តរាយធំជាងគេ ទាំងនៅក្នុង និងក្រៅផ្ទះ ដូចជាអំពើហឹង្សា ការ បង្ករបួសស្នាម ឬការបំពាន ការមិនអើពើ ឬការមិនស្និទ្ធស្នាល អំពើ ធ្វើទុក្ខបុកម្នេញ ឬការកេងប្រវ័ញ្ច។

ទ- *ដោយទទួលស្គាល់ថា* កុមារពិការ គួរតែបានទទួលយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារដទៃ និង*ដោយរំលឹកឡើងវិញពី* កាតព្វកិច្ចដែលត្រូវសម្រេចឱ្យបាននូវគោលដៅទាំងនេះរបស់រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ធ- *ដោយគូសបញ្ជាក់ពី* តម្រូវការ ដើម្បីដាក់បញ្ចូលទស្សនៈវិស័យផ្នែកយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីលើកស្ទួយជនពិការឱ្យទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។

ន- *ដោយគូសបញ្ជាក់ពីភាព*ជាក់ស្តែងដែលថា ជនពិការភាគច្រើនរស់នៅក្នុងស្ថានភាពក្រីក្រ ហើយជាមួយនឹងស្ថានភាពបែបនេះ *ដោយទទួលស្គាល់ពី* តម្រូវការដ៏សំខាន់ ក្នុងការលើកឡើងពីផលប៉ះពាល់ជាអវិជ្ជមាននៃភាពក្រីក្រដល់ជនពិការ។

ប- *ដោយចងចាំថា* លក្ខខណ្ឌនៃសន្តិភាព និងសន្តិសុខ ផ្អែកលើមូលដ្ឋាននៃការគោរពយ៉ាងពេញលេញនូវគោលបំណងនិងគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងការប្រតិបត្តិតាមលិខិតុបករណ៍សិទ្ធិមនុស្សដែលនៅមានជាធរមាន គឺជាប្រការសំខាន់ និងខានមិនបាន ដើម្បីការការពារឱ្យបានពេញលេញដល់ជនពិការ ជាពិសេស នៅពេលមានជំលោះប្រដាប់អាវុធ និងការចូលកាន់កាប់របស់បរទេស។

ផ- *ដោយទទួលស្គាល់ពី*សារៈសំខាន់នៃការទទួលបាន នូវការសម្រួលដល់បរិយាកាសផ្នែករូបវ័ន្ត សេដ្ឋកិច្ច សង្គមកិច្ច កាយ

សម្បទា សុខភាព ការអប់រំ និងព័ត៌មាននិងទំនាក់ទំនង ដើម្បីជួយឱ្យជនពិការអាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់។

ព- *ដោយយល់ច្បាស់ថា* បុគ្គលម្នាក់ៗដែលមានកាតព្វកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍របស់ខ្លួន ត្រូវមានការទទួលខុសត្រូវ ដើម្បីខិតខំប្រឹងប្រែងក្នុងការលើកស្ទួយ និងការប្រតិបត្តិតាមសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស។

ភ- *ដោយមានជំនឿថា* គ្រួសារគឺជាធាតុបង្កពីធម្មជាតិជាមូលដ្ឋាននៃសង្គម ហើយមានសិទ្ធិទទួលបាននូវការការពារពីសង្គម និងរដ្ឋ ហើយជនពិការ និងសមាជិកក្រុមគ្រួសាររបស់គេ គួរទទួលបានការការពារ និងការជួយជ្រោមជ្រែងជាចាំបាច់ ដើម្បីឱ្យក្រុមគ្រួសារគេអាចចូលរួមចំណែកធ្វើឱ្យជនពិការ ទទួលបានសិទ្ធិដោយស្មើភាពគ្នា និងដោយពេញលេញ។

ម- *ដោយមានជំនឿថា*អនុសញ្ញាអន្តរជាតិទាំងមូល និងគ្រប់ជ្រុងជ្រោយមួយដើម្បីការពារ និងលើកស្ទួយសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ នឹងរួមវិភាគទានយ៉ាងថ្លៃថ្លា ក្នុងការកែតម្រូវគុណវិបត្តិសង្គមដ៏ជ្រាលជ្រៅចំពោះជនពិការ និងលើកស្ទួយជនពិការឱ្យមានឱកាសស្មើគ្នា ក្នុងការចូលរួមលើវិស័យពាក់ព័ន្ធដល់សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទាំងក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាអារ្យប្រទេស។

**បានព្រមព្រៀងគ្នាដូចតទៅៈ**

# អនុសញ្ញាស្ដីពីសិទ្ធិជនពិការ

*(អត្ថបទសម្រាយក្រៅផ្លូវការ)*

នេះជាអត្ថបទសម្រាយដើម្បីធ្វើឱ្យមនុស្សគ្រប់រូបងាយយល់

## ១. អនុសញ្ញានេះ

អនុសញ្ញានេះ រៀបចំឡើងពីការងារអ្វីខ្លះដែលប្រទេសនានាត្រូវធ្វើដើម្បីធ្វើឲ្យប្រាកដប្រជាថាជនពិការមានសិទ្ធិដូចគ្នា ដូចបុគ្គលគ្រប់រូបដទៃទៀតដែរ។

## ២. តើពាក្យសំខាន់ៗមួយចំនួនខាងក្រោមនេះ មានន័យដូចម្ដេច?

"អនុសញ្ញានេះ" គឺជាកិច្ចព្រមព្រៀងស្ដីពីសិទ្ធិជនពិការ។

"ការប្រាស្រ័យទាក់ទង" គឺជាមធ្យោបាយ ឬវិធីនានា ដែលជួយជនពិការ ឲ្យនិយាយ និងយល់អំពីព័ត៌មានបាន។

ឧទាហរណ៍៖ កុំព្យូទ័រ វិធីងាយអាន ឬអក្សរស្ទាប។

"ការរើសអើង" គឺជាការប្រព្រឹត្តណាមួយមិនយុត្តិធម៌ ឬមិនទទួលបាននូវការផ្លាស់ប្តូរ ដែលជនពិការចង់បាន ដោយសារតែខ្លួនជាជនពិការ។

"ភាសា" គឺជាមធ្យោបាយ ដែលមនុស្សនិយាយទៅរកគ្នាទៅវិញទៅមក ដោយរាប់ទាំងភាសាសញ្ញាផងដែរ។

"ជនពិការ" សំដៅដល់បុគ្គលទាំងឡាយណា ដែលពិការតែផ្លូវកាយ ឬផ្លូវចិត្តក្នុងរយៈពេលយូរ។ ជនពិការ ក៏អាចរាប់ទាំងមនុស្សទាំងឡាយណា ដែលវិញ្ញាណ (ឧទាហរណ៍ ចក្ខុវិញ្ញាណ ការស្តាប់ ឬការនិយាយ) របស់គាត់ត្រូវបានខូចខាត។

## ៣. គំនិតជាមូលដ្ឋាន

នៅក្នុងអនុសញ្ញានេះ មានចែងពីគំនិតជាមូលដ្ឋានមួយចំនួនដែលប្រទេសនានា ត្រូវចងចាំ។ គំនិតសំខាន់ៗទាំងនេះគឺៈ

បុគ្គលម្នាក់ៗ មានសេរីភាព ធ្វើការជ្រើសរើសផ្ទាល់ខ្លួន ដោយខ្លួនឯង។ គ្មានបុគ្គលណាម្នាក់ ត្រូវបានគេរើសអើងឡើយ។

ជនពិការ មានសិទ្ធិត្រូវបានដាក់បញ្ចូលទៅក្នុងសង្គម ដូចគ្នា ដូចនឹងបុគ្គលដទៃទៀតដែរ។

ជនពិការត្រូវទទួលបានការគោរព ទោះគាត់ជានរណាក៏ដោយ។

បុគ្គលគ្រប់រូប ត្រូវមានឱកាសស្មើៗគ្នា។

បុគ្គលគ្រប់រូបត្រូវទទួលបាននូវអ្វីៗស្មើគ្នា។

បុរស និងស្រ្តី ត្រូវមានឱកាសស្មើគ្នា។

កុមារពិការ ត្រូវទទួលបានការគោរព ទោះគេជានរណាក៏ដោយ នៅពេលគេធំពេញវ័យ។

## ៤. តើប្រទេសនានា ជាសមាជិក ត្រូវធ្វើអ្វីខ្លះ?

ប្រទេសទាំងអស់ ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ ត្រូវបានគេប្រព្រឹត្តដោយស្មើភាពគ្នាជាមួយអ្នកដទៃយ៉ាងពិតប្រាកដ។

ប្រទេសទាំងនោះព្រមព្រៀងគ្នា ធ្វើកិច្ចការដូចតទៅនេះ៖

រៀបចំ តាក់តែងវិធាន និងច្បាប់នានា ដើម្បីផ្តល់សិទ្ធិដល់ជនពិការ និងធ្វើការផ្លាស់ប្តូរច្បាប់ណាមួយ ដែលមិនយុត្តិធម៌។

ធ្វើឲ្យប្រាកដប្រជាថា សិទ្ធិជនពិការដែលត្រូវបានគោរព ដោយស្មើភាពគ្នាជាមួយអ្នកដទៃ ត្រូវបានដាក់បញ្ចូល នៅគ្រប់គោលនយោបាយ។

មិនត្រូវធ្វើអ្វីមួយ ដែលប្រឆាំងនឹងអនុសញ្ញានេះឡើយ។

ធ្វើឲ្យប្រាកដប្រជាថា រដ្ឋាភិបាល និងអាជ្ញាធររបស់ខ្លួន ធ្វើអ្វីៗតាមអនុសញ្ញានេះ។

ធ្វើឲ្យអស់ពីលទ្ធភាពដែលខ្លួនអាចធ្វើបាន ដើម្បីធ្វើឲ្យប្រាកដប្រជាថាគ្មាននរណាម្នាក់រើសអើងប្រឆាំងនឹងជនពិការឡើយ។

ធ្វើឲ្យប្រាកដប្រជាថា អ្វីៗគ្រប់យ៉ាង ត្រូវបានរៀបចំឡើងសម្រាប់បុគ្គលគ្រប់រូបប្រើប្រាស់ ឬដែលអាចផ្លាស់ប្តូរបានយ៉ាងងាយស្រួល ដើម្បីឲ្យជនពិការអាចប្រើប្រាស់បាន។

ប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីជួយជនពិការ។

ផ្តល់ព័ត៌មានដែលអាចទទួលបានដោយងាយដល់ជនពិការអំពីអ្វីៗដែលអាចជួយពួកគេបាន។

ផ្សព្វផ្សាយដល់ប្រជាជនឲ្យបានយល់ដឹងអំពីអនុសញ្ញានេះ។

ប្រទេសទាំងអស់ សន្យាថានឹងធ្វើឲ្យអស់ពីលទ្ធភាពតាមដែលអាចធ្វើបាន ដើម្បីធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចទទួលបានអ្វីៗស្មើគ្នា ដូចជាលំនៅដ្ឋាន ការអប់រំ និងការថែទាំសុខភាព។

ប្រទេសទាំងអស់ ត្រូវអនុញ្ញាតឲ្យជនពិការ ចូលរួមក្នុងការធ្វើច្បាប់ និងគោលនយោបាយថ្មីៗ។

## ៥. ត្រូវស្មើភាពគ្នា

ប្រទេសនានាព្រមព្រៀងគ្នាថា បុគ្គលគ្រប់រូបត្រូវស្មើភាពគ្នានៅចំពោះមុខច្បាប់ ហើយមិនអនុញ្ញាតឲ្យមានការរើសអើងណាមួយប្រឆាំងនឹងជនពិការឡើយ។

## ៦. ស្ត្រីពិការ ត្រូវបានគេប្រព្រឹត្តដោយស្មើភាពគ្នា

ប្រទេសនានា យល់ស្របគ្នាថា ស្ត្រី និងកុមារី ដែលពិការត្រូវបានគេប្រព្រឹត្តលើ ដោយអយុត្តិធម៌ តាមវិធីច្រើនបែប ច្រើនយ៉ាងខុសៗគ្នា។

ប្រទេសទាំងនោះ ធ្វើការ ដើម្បីឲ្យប្រាកដប្រជាថា ស្ត្រី និងកុមារីពិការ មានជីវភាពពេញលេញ សេរី និងស្មើភាពគ្នា។

## ៧. កុមារពិការ ត្រូវបានគេប្រព្រឹត្តដោយស្មើភាពគ្នា

ប្រទេសនានា ព្រមព្រៀងគ្នាថា កុមារពិការមានសិទ្ធិដូចគ្នា ដូចកុមារដទៃទៀតដែរ ហើយត្រូវតែបានគេប្រព្រឹត្តលើដោយស្មើភាពគ្នាដូចអ្នកដទៃទៀតដែរ។ អ្វីៗដែលជាឧត្តមប្រយោជន៍របស់កុមារ ត្រូវតែមានសារសំខាន់បំផុត យកមកគិតគូរពិចារណា។

ប្រទេសទាំងនោះ ព្រមព្រៀងគ្នាថា កុមារពិការមានសិទ្ធិឲ្យគេដឹងឮពីយោបល់ឬកង្វល់របស់ខ្លួនចំពោះអ្វីៗទាំងអស់ដែលអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់គេ។ត្រូវផ្តល់កិច្ចគាំពារនានាដល់កុមារ ដើម្បីជួយពួកគេឲ្យសម្រេចបានតាមគោលបំណងនេះ។

## ៨. ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីពិការភាព

ប្រទេសនានា ព្រមព្រៀងគ្នាថា នឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីឲ្យបុគ្គលគ្រប់រូបយល់ដឹងថា ជនពិការមានសិទ្ធិដូចគ្នា ដូចបុគ្គលដទៃទៀតដែរ ហើយបង្ហាញជាសាធារណៈពីកិច្ចការអ្វីដែលជនពិការអាចធ្វើបាន។

ប្រទេសទាំងនោះ ត្រូវបំពេញការងារនេះ ដោយៈ

រៀបចំយុទ្ធនាការ ដើម្បីផ្លាស់ប្តូរការយល់ឃើញជាអវិជ្ជមានរបស់មនុស្សមួយចំនួនចំពោះជីវិតជនពិការ។

បង្ហាញដល់បុគ្គលគ្រប់រូប ពីការងារណាខ្លះ ដែលជនពិការអាចធ្វើបាន។

បង្ហាញដល់បុគ្គលគ្រប់រូប ពីការចូលរួមចំណែកនានា ដែលជនពិការអាចធ្វើបាន ក្នុងជីវភាពសាធារណៈ។

បង្រៀនក្មេងៗ អំពីសិទ្ធិស្មើភាពគ្នា សម្រាប់ជនពិការ។

ត្រូវធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បង្ហាញពីជនពិការឲ្យបានត្រឹមត្រូវ (ក្នុងន័យវិជ្ជមាន)។

គាំទ្របន្ថែមទៀតដល់ការងារលើកកំពស់ការយល់ដឹងអំពីពិការភាព។

## ៩. ការបន្ធូលក្ខណៈងាយស្រួល

ប្រទេសនានា គួរធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចប្រើប្រាស់អ្វីៗបានយ៉ាងប្រសើរលើគ្រប់វិស័យក្នុងជីវភាពរបស់គេ។

ជនពិការអាចប្រើប្រាស់បានយ៉ាងប្រសើរ នូវអគារសាធារណៈ ដូចជាមន្ទីរពេទ្យ និងសាលារៀន និងការដឹកជញ្ជូន។ល។

ជនពិការត្រូវទទួលបានព័ត៌មានកាន់តែប្រសើរ។

សញ្ញានានាគួរតែងាយស្រួលអាន និងជាអក្សរស្ទាប។

នៅតាមអគារសាធារណៈ គួរតែមានការណែនាំបន្ថែម និងមានអ្នកបកប្រែភាសាសញ្ញា។

គួរមានគោលការណ៍ណែនាំ អំពីវិធីប្រើប្រាស់សេវាកម្មសាធារណៈឲ្យបានកាន់តែប្រសើរ។

បុគ្គលណាក៏ដោយដែលផ្តល់សេវាកម្ម គួររៀបចំផែនការឲ្យបានល្អ ធ្វើយ៉ាងណាឲ្យជនពិការអាចប្រើប្រាស់បានដែរ។

គួររៀបចំឲ្យមានវគ្គបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល។

ត្រូវធ្វើឲ្យប្រាកដប្រជាថាជនពិការទទួលបាននូវបច្ចេកវិទ្យាថ្មីៗ

## ១០. សិទ្ធិរស់រានមានជីវិត

បុគ្គលគ្រប់រូប មានសិទ្ធិរស់រានមានជីវិត រួមទាំងជនពិការ។ ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមានឱកាសដូចគ្នា ដូចអ្នកដទៃទៀតដែរ ក្នុងការរស់នៅចិញ្ចឹមជីវិត។

## ១១. គ្រាមានអាសន្ន

ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ ត្រូវបានការពារយ៉ាងសមរម្យ នៅពេលមានស្ថានភាពគ្រោះអាសន្នដល់មនុស្សគ្រប់រូប ឧ. នៅពេលមានព្យុះសង្ឃរាជាដើម។

## ១២. ត្រូវបានប្រព្រឹត្តលើ ដោយស្មើភាពគ្នាជាមួយអ្នកដទៃ នៅចំពោះមុខច្បាប់

ជនពិការ ត្រូវទទួលបានការគោរពដោយច្បាប់ ដូចបុគ្គលដទៃទៀតដែរ។

ជនពិការមានសិទ្ធិដូចគ្នាដើម្បីធ្វើសេចក្តីសំរេចផ្ទាល់ខ្លួនអំពីបញ្ហាសំខាន់ៗ ដូចគ្នានឹងបុគ្គលដទៃទៀតដែរ។

ជនពិការ ត្រូវមានកិច្ចគាំពារសមស្រប តាមតម្រូវការ នៅពេលគេធ្វើសេចក្តីសំរេច។

ប្រសិនបើមានជនពិការណាម្នាក់ ពិតជាត្រូវការបុគ្គលណាម្នាក់ផ្សេងទៀត និយាយជំនួសខ្លួន នោះគប្បីមានវិធាន ដើម្បីធ្វើឲ្យប្រាកដប្រជាថា ការអនុវត្តន៍នេះ ត្រូវធ្វើឡើងយ៉ាងត្រឹមត្រូវ។

ជនពិការមានសិទ្ធិស្មើគ្នាដូចអ្នកដទៃ ដល់៖

សិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិ ឬទទួលយកទ្រព្យសម្បត្តិដែលគេផ្តល់ឲ្យ។

ការគ្រប់គ្រងប្រាក់កាសផ្ទាល់ខ្លួន។

លទ្ធភាពខ្ចីប្រាក់ដូចបុគ្គលដទៃទៀតដែរ។

សិទ្ធិមិនត្រូវបានគេដកហូតផ្ទះសំបែង ឬប្រាក់កាសរបស់គេដោយខុសច្បាប់ឡើយ។

## ១៣. ការទទួលបានសេវាកម្មយុត្តិធម៌

ជនពិការ ត្រូវមានសិទ្ធិទៅតុលាការ ជូននរណាម្នាក់ទៅតុលាការ ឬចូលរួមក្នុងដំណើរការក្តីនៅតុលាការ ដូចគ្នានឹងបុគ្គលដទៃទៀតដែរ។

ជនពិការត្រូវទទួលបាននូវកិច្ចគាំពារដើម្បីធ្វើឲ្យប្រាកដប្រជាថា ពួកគេទទួលបានសិទ្ធិទាំងនេះ។

ប្រទេសនានា ត្រូវរៀបចំវគ្គបណ្តុះបណ្តាលពិសេសសម្រាប់តុលាការ នគរបាល និងបុគ្គលិកពន្ធនាគារ។

## ១៤. មានសេរីភាព និងសុវត្ថិភាព

ជនពិការត្រូវមានសេរីភាព និងសុវត្ថិភាពដូចគ្នានឹងបុគ្គលដទៃទៀតដែរ។

ជនពិការមិនត្រូវបានគេបង្ខាំងទុកចោល ដោយសារតែពួកគេ ជាជនពិការនោះឡើយ លុះត្រាតែមានចែងដោយច្បាប់ កំណត់ពីមូលហេតុផ្សេងទៀតនៃការបង្ខាំងនោះ។

ប្រសិនបើជនពិការ ត្រូវបានគេបង្ខាំងទុក ដោយហេតុផលផ្សេង ពួកគេគប្បីត្រូវបានគេប្រព្រឹត្ត តាមវិធីនានា ដែលមានចែងក្នុងអនុសញ្ញានេះ។

ជនពិការ ក៏មានសិទ្ធិដូចគ្នានឹងបុគ្គលដទៃទៀតមាន ក្រោមច្បាប់អន្តរជាតិផ្សេងៗ។

អនុសញ្ញានេះ មិនបានចែងអំពីសិទ្ធិទាំងនោះទេ តែសិទ្ធិទាំងនេះ រួមបញ្ចូលៈ

ការទទួលបានព័ត៌មានអំពីសិទ្ធិរបស់ពួកគេ។

ការទទួលបានជំនួយ និងកិច្ចគាំពារ ដើម្បីទទួលបានសវនាការមួយយុត្តិធម៌ក្នុងតុលាការ។

សំណុំរឿងរបស់គេ ត្រូវបានយកមកពិនិត្យឡើងវិញឲ្យបានញឹកញាប់ដូចបុគ្គលដទៃទៀតដែរ។

## ១៥. មិនត្រូវបានគេធ្វើទារុណកម្ម ឬប្រព្រឹត្តដោយឃោរឃៅ

ជនពិការ មិនត្រូវបានគេប្រព្រឹត្តលើដោយឃោរឃៅ ឬធ្វើទារុណកម្មនោះឡើយ។

ជនពិការ មិនត្រូវបានគេយកមកធ្វើពិសោធន៍ឡើយ ជាពិសេស ពិសោធន៍ខាងវេជ្ជសាស្ត្រ (លើកលែងតែពួកគេយល់ព្រមដោយសេរី)។

ប្រទេសនានា ត្រូវតែធ្វើអ្វីៗគ្រប់យ៉ាងអាចធ្វើទៅបាន ដើម្បីធ្វើឲ្យប្រាកដប្រជាថា បញ្ហាទាំងអស់ខាងលើនេះ មិនត្រូវកើតមានឡើងឡើយ។

## ១៦.មិនត្រូវបានគេយកមកប្រើប្រាស់ឬរំលោភបំពាន

ប្រទេសនានា ត្រូវធ្វើច្បាប់ និងវិធានផ្សេងៗ ដើម្បីធ្វើឲ្យប្រាកដប្រជាថា ជនពិការត្រូវទទួលបានការការពារ ទាំងក្នុង និងក្រៅលំនៅដ្ឋានរបស់គេ ពីអំពើហិង្សា ការត្រូវគេយកមកប្រើប្រាស់ ឬការរំលោភបំពាន។

ប្រទេសនានា ត្រូវព្យាយាមផងដែរ ដើម្បីបង្ការការរំលោភបំពាន ហើយប្រទេសទាំងនោះ ត្រូវធ្វើឲ្យប្រាកដប្រជាថា មានកិច្ចគាំពារសមស្រប ព័ត៌មាន និងការបណ្ដុះបណ្ដាលអំពីវិធីសាស្ត្រឃ្លាំមើល និងធ្វើរបាយការណ៍អំពីការរំលោភបំពានទាំងនេះ។

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា សេវាកម្មដែលគាំពារដល់ជនពិការ ត្រូវបានគេត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ដើម្បីធ្វើឲ្យប្រាកដថាមិនមានការរំលោភបំពានឡើយ។

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ ដែលត្រូវបានគេរំលោភបំពាន ទទួលបានការជួយ និងកិច្ចគាំពារតាមតម្រូវការ ដើម្បីរក្សាសុវត្ថិភាពពួកគេ និងជួយពួកគេឲ្យបានធូរស្បើយពីការរំលោភបំពានវិញ។

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ប្រទេសរបស់ខ្លួន មានវិធីល្អៗក្នុងការស្វែងរកករណីរំលោភបំពាន និងនាំយកអ្នករំលោភបំពានទៅតុលាការ។

ប្រទេសនានា ត្រូវពិចារណាជាពិសេស អំពីការរំលោភបំពានលើស្ត្រី និងកុមារ។

## ១៧. ការប្រព្រឹត្តមកលើជនពិការ ជាដំបូង ថាជាមនុស្ស

ទាំងចិត្ត និងរាងកាយរបស់ជនពិការ គឺជារបស់ផ្ទាល់ខ្លួនគេ ហើយត្រូវទទួលបានការគោរពដូចគ្នា ដូចបុគ្គលដទៃទៀតដែរ។

## ១៨. ការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ

ជនពិការមានសិទ្ធិ៖

- សំរេចពីកន្លែងរស់នៅ និងផ្លាស់ប្តូរទីកន្លែង ដូចគ្នា ដូចបុគ្គលដទៃទៀតដែរ។
- ជាម្ចាស់នៃប្រទេស (ជាពលរដ្ឋស្របច្បាប់) ហើយមិនត្រូវបានគេដកហូតសិទ្ធិនេះ ដោយសារតែគេជាជនពិការនោះទេ។
- ទទួលបានឯកសារផ្សេងៗ ដូចជាលិខិតឆ្លងដែន ដែលបុគ្គលដទៃទៀតមាន។

ចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង។

កុមារពិការ មានសិទ្ធិមានឈ្មោះពីកំណើត សិទ្ធិជាពលរដ្ឋ ហើយប្រសិនបើអាច មានសិទ្ធិស្គាល់ និងសិទ្ធិទទួលបានការថែទាំពីមាតាបិតា។

## ១៩. ការរស់នៅដោយឯករាជ្យ និងជាផ្នែកមួយនៃសហគមន៍

ប្រទេសនានាត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមានជំរើសដូចគ្នា ដូចបុគ្គលដទៃទៀតដែរ អំពីវិធីរស់នៅ និងជាផ្នែកមួយនៃសហគមន៍។

ជនពិការអាចជ្រើសរើស៖

ទីកន្លែងរស់នៅ ដូចគ្នា ដូចបុគ្គលដទៃទៀតដែរ។

បុគ្គលដែលគេរស់នៅជាមួយ ដូចគ្នា ដូចបុគ្គលដទៃទៀតដែរ។

មិនរស់នៅកន្លែងពិសេសណាមួយ ដូចជាមណ្ឌល ប្រសិនបើពួកគេមិនចង់។

សេវាកម្មគាំពារផ្សេងៗជាច្រើន រាប់ទាំងគ្រឿងជំនួយផ្ទាល់ខ្លួន។

សេវាកម្មជាច្រើនផ្សេងទៀត ដូចគ្នានឹងបុគ្គលដទៃទៀត ដែលអាចជ្រើសរើស និងទទួលបានសេវាកម្មល្អៗ។

## ២០. ការចល័ត

ប្រទេសនានាត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចចល័តទៅណាមកណាបានដោយសេរី តាមដែលអាចធ្វើទៅបាន។

ប្រទេសទាំងនោះ ត្រូវៈ

- ជួយប្រជាពលរដ្ឋខ្លួន ក្នុងការចល័តទី។
- ជួយប្រជាពលរដ្ឋខ្លួន ក្នុងការទទួលបានគ្រឿងជំនួយល្អៗ និងជួយពួកគេ ឲ្យអាចចល័តទីបាន។
- ត្រូវធ្វើឲ្យប្រាកដប្រជាថា គ្រឿងជំនួយទាំងនេះ មិនមានតំលៃថ្លៃពេកនោះទេ។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រនៃការចល័តទី។
- ត្រូវណែនាំដល់ក្រុមហ៊ុន ដែលផលិតគ្រឿងជំនួយ ឲ្យគិតអំពីតម្រូវការផ្សេងៗរបស់ជនពិការ។

## ២១. និយាយពីអ្វីដែលជនពិការចង់និយាយ និងការទទួលបានព័ត៌មាន

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមានសិទ្ធិស្វែងរកព័ត៌មាន និងផ្តល់ព័ត៌មាន ហើយនិយាយពីអ្វីដែលខ្លួនចង់និយាយ ដូចគ្នានឹងបុគ្គលដទៃទៀតដែរ។

សិទ្ធិនេះ រួមមាន៖

ព័ត៌មានតាមមធ្យោបាយ ដែលជនពិការត្រូវការ។

ផ្តល់ភាសាសញ្ញា អក្សរស្ទាប និងវិធីផ្សេងៗទៀតនៃព័ត៌មាន។

ណែនាំដល់សេវាកម្មផ្សេងៗ ឲ្យផ្តល់ព័ត៌មានតាមវិធីណាដែលជនពិការអាចទទួលយកបាន។

ធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមទាំងអ៊ិនធើណិត ផ្តល់ព័ត៌មានតាមវិធីណា ដែលជនពិការអាចទទួលយកបាន។

គាំទ្រដល់ការប្រើប្រាស់ភាសាសញ្ញា។

## ២២. ភាពឯកជន

ជនពិការមានសិទ្ធិទទួលបានជីវិតឯកជន ហើយគ្មានបុគ្គលណាម្នាក់ អាចជ្រៀតជ្រែកឬចូលទៅក្នុងជីវិតឯកជនរបស់គេឡើយ។

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ព័ត៌មានផ្ទាល់ខ្លួនរបស់ជនពិការ ត្រូវបានរក្សាជាការសំងាត់ ឬទុកជាព័ត៌មានឯកជនរបស់ជនពិការ ដូចគ្នានឹងបុគ្គលដទៃទៀតដែរ។

## ២៣. ការគោរពលំនៅដ្ឋាន និងគ្រួសារ

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមានសិទ្ធិស្មើគ្នាចំពោះអាពាហ៍ពិពាហ៍ គ្រួសារ និងទំនាក់ទំនងផ្ទាល់ខ្លួន។

ប្រទេសទាំងនោះ ត្រូវធ្វើឲ្យប្រាកដប្រជាថា៖

- ជនពិការ មានសិទ្ធិស្មើគ្នាដើម្បីរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារមួយ ឲ្យតែពួកគេទាំងពីរនាក់មានបំណងប្រាថ្នា។
- ជនពិការ មានសិទ្ធិសំរេចក្នុងការបង្កើតកូន តាមចំនួន និងតាមបំណងរបស់ខ្លួន និងមិនត្រូវបានគេដកចេញនូវមេជីវិតបង្កើតកូន ប្រឆាំងនឹងឆន្ទៈរបស់ខ្លួនឡើយ។
- ជនពិការ មានសិទ្ធិរៀបចំផែនការគ្រួសារ និងទទួលបានព័ត៌មានផ្សេងៗ ដើម្បីជួយពួកគេឲ្យសំរេចពីផែនការគ្រួសារនេះ។
- ប្រទេសទាំងនោះ ត្រូវផ្តល់កិច្ចគាំពារដល់ជនពិការ ដើម្បីជួយពួកគេឲ្យអាចចិញ្ចឹមបីបាច់កូនរបស់ពួកគេ។
- កុមារពិការ មានសិទ្ធិមិនត្រូវបានបំបែកចេញពីគ្រួសារឡើយ។
- ប្រទេសទាំងនោះ ត្រូវគាំពារកុមារពិការ និងគ្រួសាររបស់គេ។

- សិទ្ធិកុមារជាសិទ្ធិត្រូវយកមកពិចារណាមុនគេ។
- ប្រទេសទាំងនោះ ត្រូវធ្វើឲ្យប្រាកដប្រជាថា កុមារមិនត្រូវបានគេបំបែកចេញពីឪពុក-ម្ដាយរបស់គេឡើយ ប្រសិនបើគេមិនចង់ លើកលែងតែមានច្បាប់ចែងថា វាជាឧត្តមប្រយោជន៍របស់កុមារ។ កុមារមិនត្រូវបានគេបំបែកចេញ ដោយសារតែពួកគេ ឬឪពុក-ម្ដាយរបស់គេពិការនោះឡើយ។

## ២៤. ការអប់រំ

ជនពិការ មានសិទ្ធិទទួលបានការអប់រំ។

ប្រទេសនានាត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមានឱកាសទៅសាលាធំៗ ហើយអាចបន្តការរៀនសូត្រពេញមួយជីវិតរបស់ខ្លួនបាន។ ធ្វើដូច្នេះ៖

- ជនពិការអាចអភិវឌ្ឍន៍ជំនាញ និងសមត្ថភាពរបស់ខ្លួន ហើយអាចឈរជើងលើទីតាំងមួយក្នុងពិភពលោកនេះ។
- ជនពិការមិនត្រូវបានគេផាត់ចេញពីប្រភេទណាមួយនៃការអប់រំឡើយ។

ជនពិការ អាចចូលរៀនសាលាល្អៗតាមមូលដ្ឋានបាន ហើយមិនត្រូវបង់ថ្លៃទេ ដូចបុគ្គលដទៃទៀតដែរ។

សេចក្តីត្រូវការរបស់ជនពិការ ត្រូវបានបំពេញ ឲ្យបានច្រើនបំផុត ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។

ជនពិការ ត្រូវទទួលបានកិច្ចគាំពារសមស្រប ក្នុងការរៀនសូត្រ

ប្រជាជន អាចរៀនអក្សរស្ទាប និងមធ្យោបាយផ្សេងៗ នៃការប្រាស្រ័យទាក់ទងតាមការចាំបាច់។

បង្រៀនភាសាសញ្ញាដល់ប្រជាជន ហើយត្រូវចាត់ទុកជាភាសាសំរាប់សហគមន៍គ-ថ្លង់។

កុមារគ-ថ្លង់ និងកុមារពិការភ្នែក ត្រូវទទួលបានការអប់រំ និងកិច្ចគាំពារត្រឹមត្រូវ សម្រាប់ពួកគេអាចរៀនសូត្របាន។

ត្រូវធ្វើឲ្យប្រាកដប្រជាថា គ្រូបង្រៀនមានជំនាញត្រឹមត្រូវ។

ផ្តល់កិច្ចគាំពារត្រឹមត្រូវដល់ជនពិការ ដើម្បីបន្តការអប់រំរបស់គេជាមនុស្សពេញវ័យ ប្រសិនបើពួកគេចង់បន្ត។

## ២៥. សុខភាព

ជនពិការ មានសិទ្ធិមានសុខភាពល្អ និងអាចទទួលបាននូវសេវាកម្មសុខភាព រួមទាំងការរៀបចំផែនការគ្រួសារផង។

ប្រទេសនានា នឹង៖

- ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ មានសិទ្ធិទទួលបានសេវាកម្មសុខភាពដូចគ្នានឹងបុគ្គលដទៃទៀតដែរ។
- ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ ទទួលបានសេវាកម្មសុខភាពតាមតម្រូវការ នៃពិការភាពរបស់គេ។
- ត្រូវធ្វើឲ្យប្រាកដប្រជាថា សេវាកម្មនានា ត្រូវស្ថិតនៅក្បែរកន្លែងជនពិការរស់នៅ។
- ត្រូវធ្វើឲ្យប្រាកដប្រជាថា មន្ត្រីឯកទេសសុខាភិបាល ផ្តល់សេវាកម្មដូចគ្នាដល់ជនពិការ ដូចនឹងការផ្តល់ឲ្យបុគ្គលដទៃទៀតដែរ
- ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការ មិនត្រូវបានគេរើសអើងក្នុងសេវាកម្មធានារ៉ាប់រងសុខភាព និងជីវិត។
- ត្រូវធ្វើឲ្យប្រាកដប្រជាថា បុគ្គលណាម្នាក់មិនត្រូវបានបដិសេធពីការថែទាំ ឬការព្យាបាល ដោយសារខ្លួនជាជនពិការនោះទេ។

## ២៦. សេវាកម្មនានា ជួយដល់ជនពិការ ឲ្យបានធូរស្បើយឡើងវិញ

ប្រទេសនានា ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចដឹកនាំជីវិតរបស់ខ្លួនដោយឯករាជ្យ និងមានសុខភាពល្អ តាមតែអាចធ្វើបាន ហើយផ្ដល់កិច្ចគាំពារដល់សុខភាព ការងារ ការអប់រំ និងសេវាកម្មសង្គមផ្សេងៗ ដើម្បីជួយដោះស្រាយបញ្ហាទាំងនេះ។

- ប្រទេសទាំងនោះ ត្រូវធ្វើឲ្យប្រាកដប្រជាថា ខ្លួនយកចិត្តទុកដាក់ដល់សេចក្ដីត្រូវការ និងភាពរឹងមាំរបស់ជនពិការនៅដំណាក់ កាលដំបូង ដើម្បីឲ្យជនពិការទទួលបាននូវកិច្ចគាំពារ និងសេវាកម្មនានា តាមតម្រូវការរបស់ពួកគេ។
- សេវាកម្មទាំងនេះ ត្រូវស្ថិតនៅក្បែរកន្លែងដែលជនពិការរស់នៅបំផុត តាមតែអាចធ្វើទៅបាន។
- បុគ្គលិកត្រូវទទួលបានការបណ្ដុះបណ្ដាល ដើម្បីបំពេញការងារ ឲ្យបានល្អ។
- ប្រទេសទាំងនោះ ត្រូវផ្ដោតទៅលើគ្រឿងជំនួយ និងឧបករណ៍ផ្សេងៗ ដែលបានផលិតឡើង ដើម្បីជួយគាំពារដល់ជនពិការ ឲ្យបានឆាប់ធូរស្បើយឡើងវិញ។

## ២៧. ការងារ

ជនពិការ មានសិទ្ធិទទួលបានការងារ ស្មើភាពគ្នាដូចបុគ្គលដទៃទៀតដែរ។

ប្រទេសនានា ត្រូវធ្វើការបន្ថែមទៀត ដើម្បីជួយជនពិការទទួលបានការងារ ហើយត្រូវជួយពួកគេទទួលបានការងារដោយៈ

- ការតាក់តែងច្បាប់ ដែលធ្វើឲ្យប្រាកដប្រជាថា ជនពិការត្រូវបានគេប្រព្រឹត្តលើដោយស្មើភាពគ្នា និងយុត្តិធម៌ នៅកន្លែងការងារ។
- ការធ្វើឲ្យប្រាកដប្រជាថា ជនពិការ មានសិទ្ធិទទួលបានការងារវិធាននានា និងប្រាក់ខែស្មើគ្នា។
- ការធ្វើឲ្យប្រាកដប្រជាថា ជនពិការមានសិទ្ធិចូលរួមក្នុងសហជីពដូចបុគ្គលដទៃទៀតដែរ។
- ការធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចចូលរួមក្នុងកម្មវិធីការងារ និងវគ្គបណ្ដុះបណ្ដាលការងារ។
- ការជួយជនពិការ ស្វែងរក និងរក្សាការងារ ក៏ដូចជាទទួលបានការងារថ្មីប្រសើរជាង។

ការជួយជនពិការ បង្កើតពាណិជ្ជកម្មផ្ទាល់ខ្លួនរបស់ពួកគេ។

ការផ្តល់ឲ្យបុគ្គលិកពិការ នូវការងារជាមួយរដ្ឋាភិបាល និងតាមទីកន្លែងផ្សេងៗទៀត ដូចជាក្រុមប្រឹក្សា និងមន្ទីរពេទ្យជាដើម។

ការជួយក្រុមហ៊ុននានា ឲ្យផ្តល់ការងារធ្វើដល់ជនពិការ។

ការធ្វើឲ្យប្រាកដប្រជាថា ជនពិការមានកន្លែងធ្វើការសមស្រប។

ការធ្វើឲ្យប្រាកដប្រជាថាជនពិការអាចមានសិទ្ធិធ្វើការងារបាន។

ជួយជនពិការ ឲ្យអាចត្រឡប់មកធ្វើការងារវិញ។

ប្រទេសទាំងនោះ ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការមិនត្រូវបានគេបង្ខំឲ្យធ្វើការ ដោយមិនបានទទួលប្រាក់កំរៃឡើយ។

## ២៨. កំរិតជីវភាពសមរម្យ

ជនពិការ និងក្រុមគ្រួសារ មានសិទ្ធិស្មើគ្នាចំពោះកំរិតជីវភាពល្អសមរម្យ រួមមានអាហារ សំលៀកបំពាក់ លំនៅដ្ឋាននិងទឹកស្អាត

ជនពិការ គប្បីអាចទទួលបានការជួយជ្រោមជ្រែង ដើម្បីធ្វើឲ្យបានកាន់តែប្រសើរដល់កំរិតជីវភាពរបស់ពួកគេ ដូចបុគ្គលដទៃទៀតដែរ។

ប្រទេសនានា គួរតែធ្វើឲ្យប្រាកដប្រជាថា៖

ជនពិការ ត្រូវទទួលបានសេវាកម្ម និងគ្រឿងជំនួយត្រឹមត្រូវទៅតាមពិការភាពរបស់ខ្លួន ក្នុងតម្លៃមួយដែលពួកគេអាចទិញបាន។

ជនពិការ ជាពិសេសស្ត្រី កុមារី និងមនុស្សចាស់ ត្រូវមានជំនួយដើម្បីឲ្យពួកគេមានកំរិតជីវភាពសមស្រប។

ជនពិការ ដែលមានជីវភាពក្រីក្រ ត្រូវទទួលបានជំនួយពីរដ្ឋ ទៅតាមតម្លៃនៃពិការភាពរបស់ពួកគេ។

ជនពិការ ត្រូវមានឱកាសដូចគ្នា ដូចបុគ្គលដទៃទៀតដែរ ក្នុងការទទួលបានប្រាក់សោធននិវត្តន៍។

ជនពិការ អាចទទួលបានកម្មវិធីលំនៅដ្ឋានសាធារណៈ។

## ២៩. ចូលរួមក្នុងសកម្មភាពនយោបាយ

ជនពិការ មានសិទ្ធិចូលរួមក្នុងឆាកនយោបាយ ដូចគ្នា ដូចបុគ្គលដទៃទៀតដែរ។

ជនពិការ មានសិទ្ធិបោះឆ្នោត តាមរយៈ៖

ការធ្វើឲ្យប្រាកដប្រជាថា ការបោះឆ្នោត មានភាពងាយស្រួលអនុវត្ត និងងាយយល់។

ការធ្វើឲ្យប្រាកដប្រជាថា ការបោះឆ្នោតត្រូវតែធ្វើជាសំងាត់។

ការអនុញ្ញាតឲ្យមានកិច្ចគាំពារជួយដល់ប្រជាជន បោះឆ្នោតតាមវិធីណាមួយ ទៅតាមតម្រូវការរបស់ពួកគេ។

ការធ្វើឲ្យប្រាកដប្រជាថា ជនពិការ អាចចូលរួមក្នុងអង្គការរដ្ឋាភិបាល និងគណៈបក្សនយោបាយ។

ការធ្វើឲ្យប្រាកដប្រជាថា ជនពិការ អាចចូលរួមក្នុងអង្គការជនពិការបាន។

ជនពិការមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជាសមាជិកសភា និងក្រុមប្រឹក្សា។

## ៣០. កីឡា និងការកំសាន្ត

ជនពិការ មានសិទ្ធិចូលរួមក្នុងកម្មវិធីកីឡា និងការកំសាន្តជាច្រើនដូចបុគ្គលដទៃទៀតដែរ។

ប្រទេសនានា ត្រូវធ្វើការ ឲ្យប្រាកដប្រជាថាៈ

ជនពិការ អាចប្រើប្រាស់អ្វីៗគ្រប់យ៉ាង ដូចជាសៀវភៅជាដើម។

ជនពិការ អាចមើលទូរទស្សន៍ ភាពយន្ត និងល្ខោន។

ជនពិការ អាចចូលទស្សនាកន្លែងផ្សេងៗ ដូចជាសារមន្ទីរ។

ជនពិការមានឱកាសធ្វើជាសិល្បករ-វិចិត្រករ ទៅតាមសិទ្ធិផ្ទាល់របស់ខ្លួន។

វិធាន និងច្បាប់នានា មិនគួរបង្កើតការលំបាកបន្ថែមទៀតដល់ជនពិការ ក្នុងការប្រើប្រាស់វត្ថុនានា ដូចជាសៀវភៅ ឬភាពយន្តជាដើម។

គ-ថ្លង់ និងវប្បធម៌ផ្សេងៗទៀត ត្រូវបានគោរព។

ជនពិការត្រូវទទួលបានកិច្ចគាំពារ ចូលរួមក្នុងកីឡាធម្មតានានា

ជនពិការអាចចូលរួមក្នុងកីឡាពិការ និងសកម្មភាពកំសាន្តផ្សេងៗ។

កន្លែងលេងកីឡា និងការកំសាន្តផ្សេងៗ អាចប្រើប្រាស់បានដោយជនពិការ។

កុមារពិការ អាចប្រើប្រាស់អ្វីៗបានដូចគ្នា ដូចអ្នកដទៃដែរ។

## ៣១. ព័ត៌មាន

ប្រទេសនានា គួរប្រមូលព័ត៌មាន និងទិន្នន័យពីជនពិការ ទៅតាមតម្រូវការ ដើម្បីជួយឲ្យអនុសញ្ញានេះបានជោគជ័យ។

ព័ត៌មានផ្ទាល់ខ្លួនរបស់ជនពិការ ត្រូវបានរក្សាជាការសំងាត់ និងឯកជនរបស់ជនពិការ។

រដ្ឋាភិបាល ត្រូវធ្វើឲ្យប្រាកដប្រជាថា ជនពិការអាចទទួលបានព័ត៌មាន និងទិន្នន័យនានាដែលរដ្ឋប្រមូលបាន ដូចបុគ្គលដទៃទៀតដែលទទួលបានព័ត៌មាន និងទិន្នន័យទាំងនេះដែរ។

## ៣២. ប្រទេសនានា ត្រូវធ្វើការរួមគ្នា

ប្រទេសនានា ត្រូវធ្វើការរួមគ្នាជាដៃគូ ដើម្បីធ្វើឲ្យអនុសញ្ញាសំរេចបានជោគជ័យ។

ប្រទេសទាំងនោះគប្បីៈ

ធ្វើឲ្យប្រាកដប្រជាថា ត្រូវធ្វើការរួមគ្នា ដោយរាប់ទាំងជនពិការ

ធ្វើឲ្យប្រាកដប្រជាថា ប្រទេសទាំងនោះ ចែករំលែកព័ត៌មាន បទពិសោធន៍ និងការបណ្ដុះបណ្ដាល ដើម្បីឲ្យប្រជាពលរដ្ឋទាំងអស់ បំពេញការងារតាមវិធីមួយដ៏ប្រសើរបំផុត។

ធ្វើឲ្យប្រាកដប្រជាថា ប្រទេសទាំងនោះធ្វើការរួមគ្នា លើការស្រាវជ្រាវ និងចែករំលែកគ្នា នូវអ្វីៗគេរកឃើញ។

## ៣៣. ធ្វើឲ្យអនុសញ្ញានេះ សំរេចបានជោគជ័យ

រដ្ឋាភិបាល ត្រូវ៖

យ៉ាងហោចណាស់ មានស្ថាប័នរដ្ឋាភិបាលមួយទទួលបន្ទុកក្នុងការធ្វើឲ្យអនុសញ្ញានេះ ដំណើរការទៅបាន។

មានវិធីសាស្ត្រ ក្នុងការវាស់វែង ពីដំណើរប្រព្រឹត្តទៅ នៃអនុសញ្ញានេះ បានល្អកម្រិតណា នៅក្នុងប្រទេសរបស់ខ្លួន។

ឲ្យជនពិការពាក់ព័ន្ធក្នុងដំណើរប្រព្រឹត្តទៅនៃអនុសញ្ញានេះក្នុងការសំលឹងមើលថាតើ ត្រូវធ្វើយ៉ាងណា ដើម្បីឲ្យអនុសញ្ញានេះដំណើរការទៅបានល្អ។

## ៣៤. គណៈកម្មាធិការសិទ្ធិជនពិការ

គណៈកម្មាធិការពិសេសមួយ នឹងត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រទេសទាំងអស់ ដែលជាសមាជិកនៃអនុសញ្ញានេះ ដើម្បីធ្វើឲ្យប្រាកដប្រជាថា អនុសញ្ញានេះត្រូវបានអនុវត្តតាមយ៉ាងត្រឹមត្រូវ។

គណៈកម្មាធិការនេះ មានមូលដ្ឋាននៅទីស្នាក់ការអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ ប្រទេសស្វីស។

## ៣៥. របាយការណ៍ពីប្រទេសពាក់ព័ន្ធនានា

ប្រទេសជាសមាជិកនីមួយៗ ត្រូវសរសេររបាយការណ៍អំពីការងាររបស់ខ្លួន បានអនុវត្តតាមអនុសញ្ញានេះ ហើយត្រូវផ្ញើទៅគណៈកម្មាធិការ ក្នុងរយៈពេលពេល២ឆ្នាំ បន្ទាប់ពីប្រទេសនោះបានយល់ព្រមចូលរួមជាសមាជិកនៃអនុសញ្ញានេះ។

បន្ទាប់ពីនោះមក ប្រទេសជាសមាជិកនីមួយៗ ត្រូវផ្ញើរបាយការណ៍ជាទៀងទាត់ រៀងរាល់៤ឆ្នាំម្តង ក៏ដូចជារបាយការណ៍បន្ថែមផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការ។

គណៈកម្មាធិការ នឹងសម្រេចពីព័ត៌មាន-ទិន្នន័យអ្វីខ្លះ ដែលប្រទេសទាំងនោះ ត្រូវដាក់ទៅក្នុងរបាយការណ៍របស់ខ្លួន។

របាយការណ៍ក៏អាចនិយាយអំពីបញ្ហាផ្សេងៗ ដែលកំពុងធ្វើឲ្យរាំងស្ទះដល់សិទ្ធិជនពិការផងដែរ។

## ៣៦. តើមានអ្វីខ្លះនឹងកើតឡើងចំពោះរបាយការណ៍

គណៈកម្មាធិការ នឹងពិនិត្យមើលរបាយការណ៍ ហើយផ្ដល់យោបល់ និងការណែនាំដល់ប្រទេសនោះវិញ ពីអ្វីដែលត្រូវធ្វើបន្ថែម។

គណៈកម្មាធិការក៏អាចស្នើសុំព័ត៌មានបន្ថែមពីប្រទេសនោះបានផងដែរ។

ប្រសិនបើរបាយការណ៍របស់ប្រទេសនោះ ផ្ញើទៅគណៈកម្មាធិការមានការយឺតយ៉ាវខ្លាំង គណៈកម្មាធិការអាចព្រមានប្រទេសនោះថា ក្នុងរយៈពេល៣ខែទៀត គណៈកម្មាធិការនឹងដំណើរការពិនិត្យមើល ពីអ្វីដែលកំពុងកើតមានឡើង នៅក្នុងប្រទេសនោះ ដោយមិនចាំបាច់មានរបាយការណ៍ពីប្រទេសនោះទេ។

ប្រទេសជាសមាជិកទាំងអស់ អាចមើលរបាយការណ៍នានានៃប្រទេសជាសមាជិកផ្សេងទៀតបាន។

ប្រទេសនីមួយៗ ត្រូវធ្វើឲ្យប្រាកដប្រជាថា សាធារណជនអាចមើលរបាយការណ៍នៃប្រទេសរបស់ខ្លួនបានហើយដឹងពីអ្វីដែលគណៈកម្មាធិការបានលើកឡើងសំរាប់ប្រទេសរបស់ខ្លួន។

គណៈកម្មាធិការ អាចផ្ញើរបាយការណ៍នៃរដ្ឋជាសមាជិកនៃអនុសញ្ញានេះ ទៅកាន់ស្ថាប័ន និងអង្គការផ្សេងៗទៀតរបស់អង្គការ សហប្រជាជាតិ ដើម្បីស្នើសុំមតិ យោបល់ ឬជំនួយ តាមការចាំបាច់។

## ៣៧. គណៈកម្មាធិការនិងប្រទេសជាសមាជិកធ្វើការរួមគ្នា

ប្រទេសជាសមាជិកនីមួយៗ ត្រូវធ្វើការរួមគ្នាជាមួយគណៈកម្មាធិការ និងជួយផ្តល់ព័ត៌មានណាមួយដល់សមាជិកគណៈកម្មាធិការ តាមតម្រូវការ។

គណៈកម្មាធិការ នឹងពិចារណាអំពីវិធីសាស្រ្ត ដែលខ្លួនអាចធ្វើការងារជាមួយប្រទេសជាសមាជិកបាន ដើម្បីឲ្យការងារនេះអាច ដំណើរការបានតាមវិធីមួយល្អប្រសើរ។

## ៣៨. តើគណៈកម្មាធិការ បំពេញការងារយ៉ាងដូចម្តេចជាមួយអង្គការផ្សេងៗទៀត

នេះគឺជាប្រការមួយយ៉ាងសំខាន់ដែលប្រទេសទាំងអស់ និង អង្គការនានា ត្រូវធ្វើការងាររួមគ្នា ដើម្បីធ្វើឲ្យការអនុវត្តអនុសញ្ញានេះ ដំណើរការទៅបានល្អ។

ស្ថាប័ន និងអង្គការផ្សេងៗ ត្រូវបានគណៈកម្មាធិការអញ្ជើញឲ្យចូលរួម ដើម្បីផ្ដល់យោបល់ និងព័ត៌មានអំពីវិស័យការងាររបស់ខ្លួន។ គណៈកម្មាធិការ អាចស្នើសុំអង្គការសិទ្ធិមនុស្សផ្សេងៗទៀត ឲ្យដាក់របាយការណ៍អំពីការងាររបស់ខ្លួនដែលពាក់ព័ន្ធ ស្របតាមអនុសញ្ញានេះ។

## ៣៩. របាយការណ៍របស់គណៈកម្មាធិការ

គណៈកម្មាធិការ ត្រូវសរសេររបាយការណ៍ រៀងរាល់២ឆ្នាំម្ដង ដាក់ជូនមហាសន្និបាត និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ។ របាយការណ៍នេះ ត្រូវដាក់បញ្ចូលយោបល់ពីប្រទេសជាសមាជិកនានា ពីអ្វីដែលគួរត្រូវធ្វើចំពោះអនុសញ្ញានេះ។

## ៤០. កិច្ចប្រជុំនៃប្រទេសជាសមាជិកនៃអនុសញ្ញានេះ

ប្រទេសជាសមាជិកទាំងអស់ ដែលបានព្រមព្រៀងអនុវត្តតាមអនុសញ្ញានេះ ត្រូវជួបប្រជុំជាទៀងទាត់។ នៅក្នុងកិច្ចប្រជុំទាំង នេះ ប្រទេសជាសមាជិកនានានឹងពិភាក្សាពីអ្វីដែលពួកគេកំពុងធ្វើ ដើម្បីធ្វើឲ្យប្រាកដប្រជាថា សិទ្ធិជនពិការត្រូវបានគោរព។